## រឿងទី២៖ អដាំ និងអេវ៉ា

**ខគម្ពីរ៖ លោកុប្បត្តិ១៖២៧**

ព្រះជាម្ចាស់បានបង្កើតមនុស្ស ជាតំណាងរបស់ព្រះអង្គ ព្រះអង្គបានបង្កើតគេឲ្យមានលក្ខណៈដូចព្រះជាម្ចាស់ ព្រះអង្គបានបង្កើតគេជាបុរសជាស្ត្រី។



ព្រះជាម្ចាស់បានធ្វើសួនឧទ្យានមួយឈ្មោះថាអេដែន ទ្រង់ធ្វើឱ្យដើមឈើគ្រប់មុខដុះចេញមក។ នៅកណ្ដាលសួនអេដែនព្រះជាម្ចាស់បានដាក់ដើមឈើជីវិតដ៏ស្រស់ស្អាត និងដើមឈើដែលនាំឱ្យស្គាល់ល្អស្គាល់អាក្រក់នៅទីនោះ

ព្រះជាម្ចាស់មានបន្ទូលទៅអដាំថា៖

«អ្នកអាចបរិភោគផ្លែឈើទាំងប៉ុន្មាន នៅក្នុងសួនឧទ្យាននេះបាន ប៉ុន្តែមិនត្រូវបរិភោគផ្លែឈើពីដើមដែលនាំឱ្យស្គាល់ល្អស្គាល់អាក្រក់ឡើយ ដ្បិតថ្ងៃណាដែលអ្នកបរិភោគផ្លែនោះ អ្នកមុខជាស្លាប់ជាមិនខាន»។

អដាំបានស្ដាប់បង្គាប់តាមព្រះបន្ទូលព្រះជាម្ចាស់។ មានថ្ងៃមួយ ពេលដែលអដាំកំពុងដេកលង់លក់ ព្រះជាម្ចាស់បានយកឆ្អឹងជំនីរបស់គាត់មកធ្វើជាស្ត្រី។

ស្ត្រីនោះមានឈ្មោះថា «អេវ៉ា»។

ប៉ុន្តែមានថ្ងៃមួយ មានសត្វពស់មួយក្បាលបានមកឯនាងអេវ៉ា។

សត្វពស់មានគម្រោងអាក្រក់ចង់ឱ្យអដាំនិងអេវ៉ាប្រព្រឹត្តអំពើបាប ដោយមិនគោរពតាមការសន្យារបស់ព្រះជាម្ចាស់ បេះផ្លែឈើស្គាល់ល្អស្គាល់អាក្រក់នោះមកបរិភោគ។

ពេលនោះអេវ៉ាបានដើរចូលទៅក្បែរដើមឈើដែលនាំឱ្យស្គាល់ល្អស្គាល់អាក្រក់ សម្លឹងមើលផ្លែដែលនៅលើដើមនោះ ឃើញថាវាមានរស់ជាតិឆ្ងាយពិសារ គួរឱ្យចង់គយគន់។ ទីបំផុត អេវ៉ាក៏បានបេះផ្លែឈើនោះមកបរិភោគ។ ហើយនាងបានយកផ្លែនោះទៅឱ្យអដាំបរិភោគដែរ។

ភ្លាមនោះស្រាប់តែមានរឿងដ៏ចម្លែកកើតឡើងមក។ ភ្លាមនោះ អដាំ និងអេវ៉ាចាប់ផ្ដើមមានអារម្មណ៍ខ្មាសអៀនចំពោះការអាក្រាតកាយរបស់ពួកគេ។ ពួកគេក៏បានបេះស្លឹកល្វាមកខ្ទាស់ធ្វើជាប៉ឹងបិទបាំងរាងកាយ ហើយរត់ទៅពួននៅក្រោយដើមឈើ។

ព្រះដែលជ្រាបគ្រប់ការទាំងអស់ ទ្រង់ឈឺព្រះទ័យជាខ្លាំង។ ព្រះជាម្ចាស់ដែលទ្រង់បានជ្រាប់ពីការនេះទាំងអស់ មានការឈឺចាប់ជាខ្លាំង។ ព្រះអង្គបានយាងមករកអដាំ។ ព្រះជាម្ចាស់បានដាក់ទោសអដាំ និងអេវ៉ាដែលមិនស្ដាប់បង្គាប់ទ្រង់ រួមទាំងសត្វពស់ផងដែរ។

ប៉ុន្តែ ទោះបី អដាំនិងអេវ៉ាបានប្រព្រឹត្តអំពើបាប ដោយសារការមិនស្ដាប់បង្គាប់ក៏ដោយ ប៉ុន្តែព្រះជាម្ចាស់នៅតែស្រឡាញ់ពួកគេ និងថែរក្សាពួកគេរហូតដល់ទីបញ្ចប់។





**សកម្មភាពទី១** សូមយករូបភ្នែក ច្រមុះ មាត់ បិទនៅមុខរបស់អដាំ និងអេវ៉ា។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ១:២៧)

ព្រះអង្គបានបង្កើតគេឲ្យមានលក្ខណៈដូចព្រះជាម្ចាស់

